# សេចក្តីថ្លែងគោលជំហរ និងធាតុចូលរបស់អង្គការសមាជិកនៃ
# អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ឆ្នាំ២០២៥

តាងនាមឱ្យអង្គការមិនមែនរដ្ឋាភិបាលជាសមាជិក នៃអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដែលបាននឹងកំពុងធ្វើការនៅក្នុងវិស័យអប់រំនៅប្រទេសកម្ពុជា យើងខ្ញុំសូមអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ចំពោះសមិទ្ធផលយ៉ាងច្រើន និងសូមកោតសរសើរចំពោះការដើរតួយ៉ាងសំខាន់ ក្នុងការជំរុញវឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពទី៤៖ ការអប់រំប្រកបដោយគុណភាព។ ប្រទេសកម្ពុជាបានដាក់ឱ្យប្រើប្រាស់នូវគំនិតផ្តួចផ្តើម នៃផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ នៅក្នុងឆ្នាំ២០១៩ ស្របតាមរបៀបវារៈអន្តរជាតិ ដែលមានចែងក្នុង សេចក្តីប្រកាសអ៊ីនឈាន់ នៅសាធារណរដ្ឋកូរ៉េ នៅក្នុងឆ្នាំ២០១២ "**ធ្វើឱ្យសិទ្ធិក្លាយជាការពិត**" ផែនការអភិវឌ្ឍន៍ជាតិ និងជាដំណើរឆ្ពោះទៅរកក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ដែលបានផ្តល់អាទិភាពដល់គោលការណ៍ "**មិនទុកនរណាម្នាក់ចោលឡើយ**"។ តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើការដើម្បីធានាថាកុមារ និងយុវជនកម្ពុជាទាំងអស់ មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំ ប្រកបដោយគុណភាព ដែលស្របតាមការប្តេជ្ញាចិត្តចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលផ្តោតការយកចិត្តទុកដាក់ក្នុងការកសាងមូលធនមនុស្ស។

ការចូលរៀននៅកម្រិតបឋមសិក្សាសម្រេចបានអត្រាពិតនៃការសិក្សា ដែលគួរឱ្យចាប់អារម្មណ៍គឺ៩៩,៦%[១] ក្នុងឆ្នាំសិក្សា២០២៣-២០២៤ ដែលបានបង្ហាញថាក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធបានយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា ព្រមទាំងការបង្កើតកម្មវិធីនានាសំដៅជំរុញ និងគាំទ្រការចូលរៀនប្រកបដោយសមធម៌។ ប្រទេសកម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ចំពោះគោលការណ៍សមភាពយេនឌ័រ ដោយបានចេញនូវក្របខណ្ឌគតិយុត្ត ជាច្រើននៅថ្នាក់ជាតិ។ លើសពីនេះ ក៏មានគោលនយោបាយដើម្បីលើកកម្ពស់បរិយាបន្នសង្គម កិច្ចការពារស្ត្រី និងក្រុមងាយរងគ្រោះ ដែលផ្តល់អាទិភាពដល់ ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី កុមារដែលមានពិការភាព កុមារជនជាតិដើមភាគតិច និងកុមារដែលជួបការលំបាក ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំប្រកបដោយសមភាព ធានាការបន្តការសិក្សារបស់សិស្ស ការបញ្ចប់ថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា។ ម្យ៉ាងវិញទៀត ការសិក្សាពេញមួយជីវិត ការអប់រំបែបឌីជីថល និងឆ្លើយតបយេនឌ័រ គឺជាប្រធានបទដ៏សំខាន់នៅក្នុងការអប់រំសម្រាប់បុគ្គលម្នាក់ៗ ដើម្បីបង្កើនសិទ្ធិ សេរីភាព សុភមង្គល និងឆ្លើយតបកំណើនតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគត។ ការសិក្សាពេញមួយជីវិត រួមបញ្ចូលនូវដំណើរការនៃការសិក្សាជាបន្តបន្ទាប់ ដែលត្រូវអនុវត្តនៅទូទាំងប្រទេស រួមមាន ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ របស់បុគ្គលគ្រប់រូប ដែលផ្តោតលើការអភិវឌ្ឍបំណិនសម្បទា វិជ្ជាសម្បទា ចរិយាសម្បទា និងសុខុមាលភាពដើម្បីជំរុញការរស់នៅប្រកបដោយសន្តិភាព និងសុខដុមរមនា។

**ទន្ទឹមនឹងសមិទ្ធផលដ៏ត្រចះត្រចង់ និងការរីកចម្រើនគ្រប់វិស័យរួមទាំងវិស័យអប់រំនៅកម្ពុជា យើងក៏សង្កេតឃើញនៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖**

[១] របាយការណ៍សន្និបាតអប់រំ ឆ្នាំ ២០២២-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ខែមេសា ឆ្នាំ២០២៤

តាមរយៈកិច្ចប្រជុំប្រចាំត្រីមាស កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត និងរបាយការណ៍ប្រចាំឆ្នាំ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលជាសមាជិករបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដើម្បីពិនិត្យមើលវឌ្ឍនភាពនៃវិស័យអប់រំទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងការប្រឈមដែលសមាជិក និងអ្នកពាក់ព័ន្ធទទួលបានតាមរយៈការកំពុងអនុវត្ត បានអនុវត្តផ្ទាល់ និងបានដឹងពីសាលារៀន ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ ជាលទ្ធផល យើងប្រមូលបានជាតុចូលដូចខាងក្រោមនេះ។

កុមារអាយុ ៣ឆ្នាំ ដល់ ៥ឆ្នាំ បានចូលរៀនមានកម្រិតទាបនៅកម្រិតមត្តេយ្យសិក្សា ដោយសារតែ កង្វះសាលាមត្តេយ្យសិក្សា កង្វះគ្រូបង្រៀនមត្តេយ្យសិក្សា គ្រឿងបរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ កង្វះអ្នកថែទាំកុមារដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងគ្រូបង្រៀនមត្តេយ្យសិក្សាដែលមិនទទួលបានការបណ្តុះបណ្តាលជាផ្លូវការជាពិសេសសម្រាប់មត្តេយ្យសិក្សាសហគមន៍ និងកង្វះការយល់ដឹងពីសារៈសំខាន់នៃការអប់រំកុមារតូច ស្របពេលឪពុកម្តាយអ្នកអាណាព្យាបាលមួយចំនួននៅមានការបារម្ភពីសុវត្ថិភាព។

ផ្អែកលើលទ្ធផលកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃការសិក្សា (PISA) របស់អង្គការOECD ឆ្នាំ២០២២ ប្រទេសកម្ពុជា ប្រឈមនឹងភាពខុសគ្នានៃការទទួលបានការអប់រំ ដោយមានត្រឹមតែ ១២% នៃសិស្សដែលឈានដល់កម្រិតបង្គួរក្នុងមុខវិជ្ជាគណិតវិទ្យា និងចំនួន៨% ក្នុងផ្នែកអំណាន។ លទ្ធផលនេះគឺនៅទាបជាងកម្រិតមធ្យមរបស់OECD។ យោងតាមរបាយការណ៍ថ្នាក់ជាតិ ស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សា នៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) ឆ្នាំ២០១៩ សិស្សថ្នាក់ទី៥ កម្ពុជាសម្រេចបានពិន្ទុមធ្យមខ្ពស់បំផុត ក្នុងផ្នែកអំណាន (២៩០) បន្ទាប់មកគណិតវិទ្យា (២៨៩) និងការសរសេរ(២៨៥)។

ការអនុវត្តតួនាទី និងការត្រួតពិនិត្យរបស់គណៈកម្មការគ្រប់គ្រងសាលារៀននៅមានកម្រិត និងការអធិការកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុក/ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ក្រុង និងសមត្ថភាពរបស់នាយកសាលាក្នុងការដឹកនាំ ក៏ប៉ះពាល់ដល់ប្រតិបត្តិការរបស់សាលារៀន និងលទ្ធផលសិក្សារបស់កុមារផងដែរ។

កង្វះគ្រូបង្រៀន គ្រូបង្រៀនដែលមានគុណវុឌ្ឍិ និងកង្វះគ្រូតាមមុខវិជ្ជា ជាពិសេសមត្ថភាពរបស់គ្រូបង្រៀនជាប់កិច្ចសន្យា ដែលមិនទទួលបានការបណ្តុះបណ្តាល នាំឱ្យការបង្រៀនមិនបានល្អ និងប្រសិទ្ធភាពខ្ពស់។

កង្វះគ្រូបង្រៀនក្នុងការជួយសិស្សដែលមានពិការភាព កង្វះអ្នកបកប្រែភាសាសញ្ញា មិនមានឧបករណ៍ជំនួយគ្រប់គ្រាន់ និងកង្វះសាលារៀនសម្រាប់កុមារមានពិការភាពសតិបញ្ញា សមត្ថភាពក្នុងការធ្វើតេស្ត និងកំណត់អត្តសញ្ញាណកុមារមានពិការភាពនៅតាមសាលារៀននៅតែជាឧបសគ្គ។

ការអនុវត្តកញ្ចប់អំណាន និងកញ្ចប់គណិតវិទ្យាថ្នាក់ដំបូង "កុមាររៀន កុមារចេះ" តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡានៅមានកំរិតនៅឡើយ ខណៈដែលការផ្លាស់ប្តូរគ្រូបង្រៀនដែលបានឆ្លងកាត់វគ្គកញ្ចប់អំណាន និងកញ្ចប់គណិតវិទ្យាថ្នាក់ដំបូងនៅតាមមូលដ្ឋានជាឧបសគ្គមួយដ៏ធំ។ ទន្ទឹមនឹងនេះ កង្វះសៀវភៅជំនួយភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង ដែលជាគ្រឹះនៃការរៀនដើម្បីអាន ក៏ជាបញ្ហាប្រឈមផងដែរ។ ប្រការនេះទាមទារឱ្យសាលារៀន ត្រូវរៀបចំផែនការ និងថវិកាដែលឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងរបស់សាលារៀន។

វិសមភាពយេនឌ័រ នៅក្នុងវិស័យអប់រំនៅតែជាប្រព័ន្ធបញ្ហាស្មុគស្មាញ និងស៊ីជម្រៅ ដែលបន្តកើតមានជាច្រើនជំនាន់មកដល់បច្ចុប្បន្ន ចាប់ពីកម្រិតមូលដ្ឋានរហូតដល់ថ្នាក់ជាតិ ហើយវាជះឥទ្ធិពលជាអវិជ្ជមានដល់ការសិក្សារបស់កុមារ ជាពិសេសកុមារី និងជនជាតិដើមភាគតិច។ បញ្ហាត្រូវបានលើកឡើងរួមមានវិសមភាពតួនាទីប្រពៃណី ឧបសគ្គសេដ្ឋកិច្ចគ្រួសារ កង្វះហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ពីសហគមន៍មកសាលារៀន សម្ភារៈបរិក្ខារជាមូលដ្ឋាន ដូចជា បង្គន់អនាម័យ ការបែងចែកការប្រើប្រាស់បង្គន់តាមភេទ និងពិការភាព ការផ្គត់ផ្គង់ទឹក ការប្រើប្រាស់ប្រព័ន្ធ

អ៊ីនធឺណិត និងអន្តេវាសិកដ្ឋានមានកំណត់ កាន់តែរឹតត្បិតឱកាសសិក្សា។ ការបង្រៀនឆ្លើយតបយេនឌ័រ គឺមានឥទ្ធិពលវិជ្ជមានលើការរៀនសូត្រទាំងក្មេងប្រុស ក្មេងស្រី កុមារដែលមានពិការភាព និងកុមារជនជាតិដើមភាគតិច។

ឌីជីថលសម្រាប់ការអប់រំ គឺមានសារៈសំខាន់យ៉ាងខ្លាំង ហើយក៏ជាអាទិភាពរបស់ប្រទេសកម្ពុជាផងដែរ។ ប៉ុន្តែវាមានការប្រឈមនឹងឧបសគ្គយ៉ាងខ្លាំងនៅក្នុងបរិបទនៃការអប់រំ ដោយសារតែការផ្គត់ផ្គង់អគ្គិសនី កង្វះខាតឧបករណ៍ និងការចូលប្រើអ៊ីនធឺណិត ជាពិសេសនៅតំបន់ជនបទ។ អក្ខរកម្មឌីជីថលក្នុងចំណោមគ្រូបង្រៀន និងសិស្ស បានរាំងដល់ការសិក្សាតាមអ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាព ហើយមាតិកាឌីជីថលដែលមានគុណភាពជាភាសាខ្មែរគឺនៅមិនទាន់បានទូលំទូលាយនៅឡើយ។ ការបញ្ចូលបច្ចេកវិទ្យាទៅក្នុងការបណ្តុះបណ្តាលគរុកោសល្យ គ្រូបង្រៀនមិនទាន់គ្រប់គ្រាន់ អាចធ្វើឱ្យលទ្ធផលសិក្សាឌីជីថលនៅមានកម្រិតទាប និងកង្វះខាតថវិកាដែលជាប់លាប់ បានរាំងដល់គំនិតផ្តួចផ្តើមសិក្សាឌីជីថលប្រកបដោយនិរន្តរភាព។

**យើងខ្ញុំសូមសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡា ពិចារណានូវចំណុចមួយចំនួន ដូចខាងក្រោម៖**

១ ដើម្បីការធានាបាននូវមូលនិធិបានគ្រប់គ្រាន់ និងសមធម៌សម្រាប់ការអប់រំ និងការសិក្សាពេញមួយជីវិត យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាល បែងចែកយ៉ាងហោចណាស់ ៤-៦% នៃផលិតផល ក្នុងស្រុកសរុប និង/ឬ ១៥-២០% នៃការចំណាយសាធារណៈសរុបសម្រាប់ការអប់រំ ដើម្បីឱ្យវិស័យអប់រំ រីកចម្រើនកាន់តែហ័ស ការអប់រំមាននិរន្តរភាព ព្រមទាំងទទួលបានសមិទ្ធផលសមស្របតាមការគ្រោងទុករបស់យុទ្ធសាស្ត្របញ្ចកោណ។

២ ការធ្វើសវនកម្មជាទៀងទាត់ ការបង្កើនប្រសិទ្ធភាពនៃធនធានហិរញ្ញវត្ថុ ការពង្រឹងគណនេយ្យភាព និងតម្លាភាព៖ បង្កើតក្របខ័ណ្ឌដ៏រឹងមាំ ដើម្បីធានានូវគណនេយ្យភាព និងតម្លាភាពក្នុងការបែងចែក និងការប្រើប្រាស់មូលនិធិអប់រំ ពង្រឹងសមត្ថភាព ទំនុកចិត្ត និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។

៣ វិនិយោគ និងអនុវត្តប្រព័ន្ធត្រួតពិនិត្យ ព្រមទាំងការវាយតម្លៃប្រកបដោយប្រសិទ្ធិភាព ដើម្បីតាមដានវឌ្ឍនភាព កំណត់បញ្ហាប្រឈម និងកសាងប្រព័ន្ធព័ត៌មានមួយសម្រាប់កែលម្អកម្មវិធី។

៤ ជំរុញការបង្កើតផែនការសកម្មភាពស្តីពីការអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ និងបង្កើនថវិកានៃកម្មវិធីអប់រំកុមារតូច ព្រមទាំងពន្លឿនការពង្រីកមត្តេយ្យសិក្សា នៅក្នុងសាលាបឋមសិក្សារដ្ឋ ការបើកទារកដ្ឋាន និងកៀរគថវិកា ក្នុងការបង្កើនចំនួនមត្តេយ្យសហគមន៍ឱ្យច្រើន ហើយកាន់តែខិតជិតដល់ប្រជាពលរដ្ឋ។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងធនធានរបស់សាលារៀន អាចជួយពង្រីកលទ្ធភាពទទួលបានសេវាអប់រំកុមារតូច។

៥ បន្ថែមការវិនិយោគលើការកសាងសមត្ថភាពរបស់គ្រូបង្រៀនកុមារតូច និងអ្នកថែទាំកុមារ ដោយផ្តល់ឱ្យនូវការបណ្តុះបណ្តាលជាប្រចាំ ជាពិសេសអំឡុងពេលមហាវិស្សមកាល ការពង្រឹងសមត្ថភាពគ្រូបង្រៀននូវជំនាញគរុកោសល្យចាំបាច់ និងបរិយាបន្ន ដូចជាការគ្រប់គ្រងថ្នាក់រៀនប្រកបដោយ ប្រសិទ្ធភាព ការធ្វើតេស្ត វាយតម្លៃសិស្ស ដើម្បីជូនដំណឹងដល់ការបង្រៀន ក្នុងការបង្កើនប្រសិទ្ធភាព និងលទ្ធផលសិក្សារបស់សិស្ស។

៦ ពង្រីកការអនុវត្តស្តង់ដាសាលាគំរូ៖ ផ្តល់អាទិភាព ដល់ការផ្តល់មូលនិធិដែលជាប់លាប់ ភ្ជាប់ទៅនឹងសូចនាករសម្រាប់ការអនុវត្ត ដើម្បីធានាគុណភាពប្រកបដោយនិរន្តរភាព ផ្តល់ការគាំទ្រ និងតម្រង់ទិសដល់សាលារៀនដែលត្រៀមខ្លួនក្លាយជាសាលាគំរូ តាមរយៈការចែករំលែកចំណេះដឹង និងការផ្សព្វផ្សាយការអនុវត្តល្អ។ លើសពីនេះទៅទៀត ការដាក់បញ្ចូលស្តង់ដាសាលាគំរូ ទៅក្នុងកម្មវិធីបណ្តុះ បណ្តាលនឹង

ធានាថា នាយកនាយិការសាលារៀន ត្រូវបានបំប៉នសមត្ថភាព ដើម្បីអនុវត្តបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ សូមក្រសួងអប់រំ យុវជន និងកីឡា ពិចារណាលើចំណុចមួយចំនួនបន្ថែមទៀតដូចខាងក្រោម៖

- វិនិយោគលើការអភិវឌ្ឍបណ្ណាល័យនៅក្នុងសាលារៀន រួមទាំងការផ្តល់សៀវភៅដែលសមស្របតាមអាយុ និងធនធានសិក្សាផ្សេងៗទៀត តាមរយៈការស្វែងរកភាពជាដៃគូជាមួយបណ្ណាល័យ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ដើម្បីពង្រីកលទ្ធភាពទទួលបានធនធានសម្រាប់បណ្ណាល័យ។
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅតាមសាលារៀន ដើម្បីគាំទ្រការអប់រំឌីជីថល។ ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដល់គ្រូបង្រៀនក្នុងការបញ្ចូលបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាពក្នុងការបង្រៀនរបស់ពួកគេ។ បណ្តុះបណ្តាលបន្ថែមដល់គ្រូបង្រៀន ឱ្យចេះប្រើប្រាស់ថ្នាលឌីជីថលនានារបស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីឱ្យគ្រូមានឱកាសពង្រឹងសមត្ថភាពដោយខ្លួនឯង។
- ជ្រើសរើសនាយកសាលាដែលមានសមត្ថភាព គុណសម្បត្តិ និងផ្តល់ការបណ្តុះបណ្តាលជាកាតព្វកិច្ច ក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពដូចជា ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស និងការរៀបចំផែនការយុទ្ធសាស្ត្រសាលារៀន។
- ពង្រីកការបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនលើការធ្វើតេស្តដើម្បីកំណត់អត្តសញ្ញាណពិការភាព និងផ្តល់ការកសាងសមត្ថភាពដល់គ្រូបង្រៀន លើការជួយដល់សិស្សដែលមានពិការភាពក្នុងថ្នាក់ ដោយផ្តល់នូវសម្ភារៈបង្រៀននិងរៀន ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ជំនួយសម្រាប់សិស្សដែលមានពិការភាព។

៧ បង្កើតគោលនយោបាយដែលលើកទឹកចិត្តដល់គ្រូបង្រៀន និងបង្កើនការបណ្តុះបណ្តាលគ្រូ ជាពិសេសគ្រូបង្រៀននៅតំបន់ជនបទ។ ក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើនការវិនិយោគលើការអនុវត្តកម្មវិធីអភិវឌ្ឍន៍អាជីពជាប្រចាំ លើការវាយតម្លៃរបស់គ្រូជាប្រចាំ ផ្តោតលើការអភិវឌ្ឍ និងប្រឹក្សាគរុកោសល្យ ជាពិសេសការបណ្តុះបណ្តាលគ្រូបង្រៀនជាប់កិច្ចសន្យា ដើម្បីធានាគុណភាពបង្រៀន និងរៀន។

៨ សូមធ្វើយ៉ាងណាឱ្យតម្លៃសៀវភៅកញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ដំបូងមានតម្លៃសមរម្យ ដើម្បីឱ្យគ្រួសារសិស្សក្រីក្រ និងសិស្សជួបការលំបាកអាចមានលទ្ធភាពទិញប្រើប្រាស់បានគ្រប់ៗគ្នា។

៩ ផ្តល់អាទិភាព និងដោះស្រាយតម្រូវការជាក់លាក់ ដល់គោលដៅអន្តរាគមន៍ដូចជា ក្រុមជនដែលមានពិការភាព ជនជាតិដើមភាគតិច និងកុមារមកពីមជ្ឈដ្ឋានជួបការលំបាករួមមាន៖ ការផ្តល់អាហារូបករណ៍ ការអនុវត្តកម្មវិធីអប់រំបរិយាបន្ន និងការដោះស្រាយឧបសគ្គសំខាន់ៗក្នុងការចូលរៀន ជាពិសេសនៅតំបន់ដាច់ស្រយាល និងនៅតាមគ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីធានាបានឱកាសសិក្សាពេញលេញប្រកបដោយសមធម៌ និងបរិយាបន្ន។

១០ បន្តការយកចិត្តទុកដាក់លើការអប់រំយេនឌ័រ និងវិភាគរកមូលហេតុដែលធ្វើឱ្យក្មេងស្រីមិនអាចបន្តការសិក្សា និងមូលហេតុដែលក្មេងប្រុសមិនបានទទួលលទ្ធផលល្អ និងប្រឈមក្នុងការបោះបង់ការសិក្សា។

# អង្គការសមាជិកដែលបានចូលរួមផ្តល់យោបល់ លើសេចក្តីថ្លែងគោលជំហរ និងធាតុចូល

| ល.រ | ឈ្មោះអង្គការសមាជិក | ល.រ | ឈ្មោះអង្គការសមាជិក |
|---|---|---|---|
| ១ | សមាគមបណ្តុះកុមារ | ២៦ | អង្គការមូលនិធិផ្កាយសមុទ្រឥណ្ឌូចិន |
| ២ | សមាគមភ្នំនាងកង្រី | ២៧ | អង្គការរួមផ្លូវដែកម្ពុជា |
| ៣ | សមាគមអភិវឌ្ឍន៍ស្រ្តីកម្ពុជា | ២៨ | អង្គការលើកកម្ពស់យុវជន |
| ៤ | អង្គការឆាលហ្វានកម្ពុជា | ២៩ | អង្គការវើលវីញ |
| ៥ | អង្គការឌីវីអីអន្តរជាតិប្រចាំកម្ពុជា | ៣០ | អង្គការវេទិកាសេវាសន្តិភាពស៊ីវិល |
| ៦ | អង្គការពង្រឹងយុវជនកម្ពុជា | ៣១ | អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា |
| ៧ | អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ | ៣២ | អង្គការសង្គ្រោះកុមារកម្ពុជា |
| ៨ | អង្គការក្តីសង្ឃឹមដ៏ធំ | ៣៣ | អង្គការសង្គ្រោះជនងាយរងគ្រោះកម្ពុជា |
| ៩ | អង្គការគម្រោងពុទ្ធិកបណ្ណាល័យកម្ពុជា | ៣៤ | អង្គការសន្តិស្ម័គ្រចិត្ត |
| ១០ | អង្គការគាំទ្រការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន | ៣៥ | អង្គការសហគមន៍អភិវឌ្ឍន៍សង្គមកម្ពុជា |
| ១១ | អង្គការគ្រួសារថ្មី | ៣៦ | អង្គការសហព័ន្ធសាលារៀនពិភពលោក |
| ១២ | អង្គការគ្រួសារយើង | ៣៧ | អង្គការស៊ីប៉ា |
| ១៣ | អង្គការឆត្របៃតង | ៣៨ | អង្គការស៊ីហ្វា-កម្ពុជា |
| ១៤ | អង្គការជំនួយជនបទ | ៣៩ | អង្គការស៊ីអារអែស |
| ១៥ | អង្គការទស្សនពិភពលោក | ៤០ | អង្គការសាមគ្គី |
| ១៦ | អង្គការទីកន្លែងអាស៊ីហ្វា | ៤១ | អង្គការសាលារៀនទន្សាយ |
| ១៧ | អង្គការប៉ាសឺរ៉ែល នុម៉េរិក ខេមបូឌា | ៤២ | អង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការ |
| ១៨ | អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ | ៤៣ | អង្គការហ្វូដណេបឺសកម្ពុជា |
| ១៩ | អង្គការពន្លកថ្មីនៃកម្ពុជា | ៤៤ | អង្គការហ្វេមកម្ពុជា |
| ២០ | អង្គការពន្លឺកម្ពុជា | ៤៥ | អង្គការឡូធឺសអៅរីកខេមបូឌា |
| ២១ | អង្គការពិភពកុមារនិងអភិវឌ្ឍន៍ | ៤៦ | អង្គការអនុផលព្រៃឈើ |
| ២២ | អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល | ៤៧ | អង្គការអប់រំពិភពលោក |
| ២៣ | អង្គការភ្លែនអន្តរជាតិកម្ពុជា | ៤៨ | អង្គការអាជ្រា |
| ២៤ | អង្គការមណ្ឌលកុមារកំព្រាសំរាប់ក្មេងកម្ពុជា | ៤៩ | អង្គការអេដអេអាកស្យុង |
| ២៥ | អង្គការមូលនិធិកុមារកម្ពុជា | ៥០ | អង្គការអេហ្វអេកកម្ពុជា |